**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ៦១) |
| **ដាក់ទៅ** | : | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | : | ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 13-Sep-2019, 14:05
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈ:**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គបុរេជំនុំជម្រះ:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាជាតិ**
**សុំដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ**
**របស់ ស.ច.ស.អ ជាភាសាខ្មែរជាមុន**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញាអន្តរជាតិ (បម្រុង)**

លោកស្រី Brenda J. HOLLIS

**ចម្លងជូន:**

**សហព្រះរាជអាជ្ញាជាតិ**

លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គីមសាន

ចៅក្រម Olivier BEAUVALLET

ចៅក្រម ន័យ ថុល

ចៅក្រម Kang Jim BAIK

ចៅក្រម ហួត វុទ្ធី

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៃសំណុំរឿង០០៤**

**សហមេធាវី យឹម ទិត្យ**

លោក សូ មូស្សេទ្ធី

លោកស្រី Suzana TOMANOVIĆ

# ចម្លើយតប

1. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (“ស.ច.ស.អ”) បានចេញដីកាដំណោះស្រាយ (“ដីកាបញ្ជូនរឿងទៅជំនុំជម្រះ”) ដោយចោទប្រកាន់ យឹម ទិត្យ ចំពោះអំពីប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ និងឲ្យបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ[1]។ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាជាតិ (“ស.ព.ជ”) បានផ្ដល់សេចក្ដីជូនដំណឹងថា លោកស្រីមានចេតនាប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ[2]។ នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ លោកស្រីបានស្វែងរកការអនុញ្ញាតពីអង្គបុរេជំនុំជម្រះ ដើម្បីដាក់បណ្ដឹងឧទ្ធរណ៍របស់លោកស្រីជាភាសាខ្មែរជាមុនសិន ដោយសំណៅបកប្រែជាភាសាអង់គ្លេសនឹងដាក់តាមក្រោយក្នុងពេលឆាប់ៗតាមដែលអាចធ្វើបាន[3]។

2. សហព្រះរាជអាជ្ញាអន្តរជាតិមិនជំទាស់នឹងសំណើរបស់ ស.ព.ជ ដែលស្នើសុំដាក់តែមួយភាសាខ្មែរជាមុន ដោយសំណៅបកប្រែនឹងដាក់តាមក្រោយនេះទេ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៩ | លោក **William SMITH**<br>សហព្រះរាជអាជ្ញាអន្តរជាតិរងជួស<br>លោកស្រី **Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ (បម្រុង) | ភ្នំពេញ | |

[1] ឯកសារ **D382** ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ KH 01624968-81។ ការបកប្រែជាភាសាខ្មែរ ត្រូវបានជូនដំណឹងដល់ភាគីនានា ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩។

[2] ឯកសារ **D382/4** សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាជាតិ អំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ បានជូនដំណឹងដល់ភាគីនានា នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩។

[3] ឯកសារ **D382/7** សំណើរបស់សហព្រះរាជអាជ្ញាជាតិសុំដាក់សារណាបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជាភាសាខ្មែរជាមុនសិន ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩។